# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ.....០១...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការបង្កើតទូរគមនាគមន៍កម្ពុជា ជាសហគ្រាសសាធារណៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០១៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រម លេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តន៍ព្រះរាជក្រម ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីស្នងការគណនី នៃសហគ្រាសសាធារណៈ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនា ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៤

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ត្រូវបានបង្កើត **ទូរគមនាគមន៍កម្ពុជា** អក្សរកាត់ថា **ទ.ក.** ជាភាសាអង់គ្លេស **TELECOM CAMBODIA** អក្សរកាត់ថា **T.C.** ។

**ទ.ក.** ជាសហគ្រាសសាធារណៈ មានលក្ខណៈជាក្រុមហ៊ុនរដ្ឋ ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រោមអាណាព្យាបាល ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ទ.ក.** មានទីស្នាក់ការនៅរាជធានីភ្នំពេញ អាស័យដ្ឋានលេខ ៩៥-៩៧ វិថីព្រះសីហនុ កែងផ្លូវលេខ ១០៥ សង្កាត់បឹងព្រលឹត ខ័ណ្ឌ ៧ មករា រាជធានីភ្នំពេញ និងអាចផ្លាស់ប្តូរទីកន្លែងបានតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។

**ទ.ក.** ជានីតិបុគ្គលមានស្វ័យភាពបច្ចេកទេស រដ្ឋបាល និងហិរញ្ញវត្ថុ ។

**មាត្រា២.-**

**ទ.ក.** ទទួលពីរដ្ឋនូវសិទ្ធិ និងកាតព្វកិច្ចទាំងឡាយ ដើម្បីបំពេញបេសកកម្ម ស្របតាមកម្មវត្ថុរបស់ខ្លួន ។

**ទ.ក.** មានទិសដៅ និងភារកិច្ច ដូចខាងក្រោម ៖

១ - ធ្វើប្រតិបត្តិការបណ្តាញ និងផ្តល់សេវាទូរគមនាគមន៍ក្នុងប្រទេស និងក្រៅប្រទេស (Domestic and International Telecommunications Network Operator and Services Provider) តាមប្រព័ន្ធវិទ្យុគមនាគមន៍ (Radio Communications) តាមផ្កាយរណប (Satellite) ខ្សែកាបអុបទិក (Optical Fiber Cable) តាមខ្សែកាបក្រោមបាតសមុទ្រ (Sub-Marine Cable) ក្នុងនោះរួមមាន ៖

១.១- ចរាចរទូរស័ព្ទ និង ទូរសារ ( Telephone & Fax Traffic ) ។

១.២- គមនាគមន៍ទិន្នន័យ ( Data Communication ) ។

១.៣- អ៊ិនធឺណែត និង សារអេឡិចត្រូនិក ( Internet and E-mail ) ។

១.៤- បរិបថជួលជាវ ( Private Leased Circuit ) (PLC) ។

២- ផ្តល់សេវាលើការបញ្ជូនរូបភាពដោយផ្ទាល់ (TV Transmission point to point ) ។

៣- ផ្តល់សេវាលើការប្រើប្រាស់ប្រព័ន្ធផ្កាយរណបតូចៗ (VSAT System) ។

៤- ធ្វើសេវាកម្មវិស័យទូរគមនាគមន៍ ព្រមទាំងព័ត៌មានវិទ្យានៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដែលស្របតាមអាជ្ញាប័ណ្ណចេញដោយក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ។

៥- ធ្វើឱ្យវិស័យទូរគមនាគមន៍ និង ព័ត៌មានវិទ្យានៅទូទាំងព្រះរាជាណាចក្រកម្ពុជា មានការរីកចំរើន និងទំនើបទៅតាមបច្ចេកវិជ្ជា ។

៦- ផ្តល់សេវាវិស័យទូរគមនាគមន៍ផ្សេងៗទៀត ។

៧- សហការជាមួយក្រុមហ៊ុនក្នុងប្រទេស ឬ ក្រៅប្រទេស ក្នុងការធ្វើសេវាកម្ម អាជីវកម្ម ។

៨- ចុះកិច្ចសន្យាជួលជំនាញការតាមសេចក្តីត្រូវការ ។

៩- ចុះកិច្ចសន្យាជួលជាវប្រព័ន្ធទូរគមនាគមន៍នានា ជាមួយក្រុមហ៊ុនក្នុងប្រទេស ឬ ក្រៅប្រទេស ។

១០- កំណត់ថ្លៃសេវាទូរស័ព្ទក្នុងប្រទេសដោយខ្លួនឯង រីឯថ្លៃសេវាទូរស័ព្ទអន្តរជាតិអនុវត្តតាមចន្លោះថ្លៃមួយ ដែលត្រូវបានកំណត់ដោយក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ។

១១- បង្កើតសាខានានាក្នុងព្រះរាជាណាចក្រកម្ពុជា ។

១២- ចុះកិច្ចសន្យាជាមួយក្រុមហ៊ុនក្នុងប្រទេស ឬក្រៅប្រទេសក្នុងការផលិត ឬតម្លើងឧបករណ៍បរិក្ខារខាងវិស័យទូរគមនាគមន៍ និងព័ត៌មានវិទ្យា ។

១៣- មានសិទ្ធិក្នុងការសុំចូលដល់ទីកន្លែងសាធារណៈ ឬលំនៅដ្ឋានឯកជន ដើម្បីតម្លើង ឬជួសជុលបណ្តាញ ទូរគមនាគមន៍ ស្របតាមសមត្ថកិច្ចរបស់ខ្លួន ។

**មាត្រា៣.—**

**ឧ.ត.** ត្រូវគោរពរបបពន្ធ និង អាករស្របតាមច្បាប់ និង បទប្បញ្ញត្តិជាធរមាន ។

**មាត្រា៤.—**

ដើមទុនដំបូងរបស់ **ឧ.ត.** ត្រូវកំណត់ឡើងតាមតុល្យការដំបូង ដែលទទួលការឯកភាពពី ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ពេលអនុក្រឹត្យនេះចូលជាធរមាន **ឧ.ត.** ត្រូវចាត់ទុកជាម្ចាស់កម្មសិទ្ធិពេញច្បាប់ជំនួសរដ្ឋលើទ្រព្យសម្បត្តិទាំងអស់ ដែលរដ្ឋបានប្រគល់អោយហើយដែលបានកត់ត្រាក្នុងបញ្ជីសារពើភ័ណ្ឌ ។

**មាត្រា៥.—**

បុគ្គលិករបស់ **ឧ.ក.** ត្រូវជ្រើសរើសពីចំណោមមន្ត្រីនៃមុខងារសាធារណៈ របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងអាចជ្រើសរើសតាមកិច្ចសន្យាក្នុងករណីចាំបាច់ ។ បុគ្គលិករបស់ **ឧ.ក.** ត្រូវគ្រប់គ្រងដោយលក្ខន្តិកៈ ដោយឡែក ដែលអនុម័តដោយក្រុមប្រឹក្សាភិបាល ។

## ជំពូកទី ២
## ការដឹកនាំ និង ការគ្រប់គ្រង

**មាត្រា៦.—**

**ឧ.ក.** ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសិទ្ធិយ៉ាងពេញលេញ ដើម្បីបំពេញការងារក្នុងក្របខ័ណ្ឌនៃបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និង លក្ខន្តិកៈរបស់ខ្លួន ។

ក្រុមប្រឹក្សាភិបាលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| - តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ១រូប | ជាប្រធាន |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ១រូប | ជាសមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១រូប | ជាសមាជិក |
| - តំណាងក្រសួង មហាផ្ទៃ | ១រូប | ជាសមាជិក |
| - អគ្គនាយក **ឧ.ក** . | ១រូប | ជាសមាជិក |
| - តំណាងនិយោជិតរបស់ **ឧ.ក.** | ១រូប | ជាសមាជិក |
| - តំណាងសភាពាណិជ្ជកម្ម | ១រូប | ជាសមាជិក |

**មាត្រា៧.—**

សមាជិកក្រុមប្រឹក្សាភិបាល ត្រូវជ្រើសតាំងក្នុងចំណោមមន្ត្រីដែលសកម្ម ធ្លាប់បានបំរើការងារយ៉ាងតិច ៥ (ប្រាំ) ឆ្នាំ ឬជាឥស្សរៈជនដែលមានអាយុមិនលើសពី៦៥ (ហុកសិបប្រាំ) ឆ្នាំ និងមានបទពិសោធការងារគ្រប់គ្រាន់ព្រមទាំងមានជំនាញខ្ពស់ក្នុងវិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្រ ឬ នីតិសាស្ត្រ ដែលមានសញ្ជាតិខ្មែរ និង មិនដែលត្រូវផ្តន្ទាទោសពីបទមជ្ឈិម ឬ ឧក្រិដ្ឋ ។

សមាជិកក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងដោយអនុក្រឹត្យសំរាប់អាណត្តិ ៣(បី) ឆ្នាំ ។ អាណត្តិនេះអាច

បញ្ចប់ ឬអាចបន្តទៀតបានដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួង ឬ អង្គភាពដែលខ្លួនតំណាងឱ្យ ។

តំណាងនិយោជិត ត្រូវជ្រើសរើសដោយបោះឆ្នោត ក្នុងចំណោមនិយោជិតរបស់ **ឧ.ក.** ។

**មាត្រា៨.-**

ក្រុមប្រឹក្សាភិបាលមានសិទ្ធិពេញលេញដើម្បីសម្រេចក្នុងនាម **ឧ.ក.** ក្នុងការរៀបចំលិខិតស្នាម ឯកសារផ្សេងៗ ទាក់ទងទៅនឹងកម្មវត្ថុរបស់សហគ្រាស ស្របតាមច្បាប់ជាធរមាន ។

**ក្រុមប្រឹក្សាភិបាលមានតួនាទីជាអាទិ៍ ៖**

១- សម្រេចលើគំរោងផែនការរបស់សហគ្រាស ដូចមានចែងក្នុងមាត្រា១៦ នៃអនុក្រឹត្យនេះ

២- វាយតម្លៃរៀងរាល់ពេល នូវលទ្ធផលដែលបានគ្រោងទុក ព្រមទាំងចាត់វិធានការដើម្បីកែសម្រួលឱ្យបានសមស្របតាមសភាពការណ៍

៣- លើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងរបាយការណ៍សកម្មភាពរបស់ **ឧ.ក.**

៤- លើសំណើសមស្របរបស់អគ្គនាយក នូវរចនាសម្ព័ន្ធនិងបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស ព្រមទាំងលក្ខន្តិកៈ និងកាំប្រាក់បៀវត្ស ប្រាក់រង្វាន់ ប្រាក់ឧបត្ថម្ភផ្សេងៗ សំរាប់បុគ្គលិកដោយអនុលោមតាម ច្បាប់ និង បទប្បញ្ញត្តិទាំងឡាយជាធរមាន

៥- សម្រេចលើកិច្ចសន្យា និងអនុសញ្ញាដែល **ឧ.ក.** ជាភាគីហត្ថលេខី ស្របតាមល័ក្ខខ័ណ្ឌ និងបែបបទដូចមានចែងក្នុងបទបញ្ជាជាធរមាន

៦- បង្កើត បើក ឬបិទការិយាល័យ និងទីស្នាក់ការគ្រប់កន្លែងរបស់ **ឧ.ក.** តាមការវិនិច្ឆ័យរបស់ខ្លួន។

៧- លើការប្រើប្រាស់ប្រាក់ចំណេញរបស់ **ឧ.ក.** ស្របតាមលក្ខន្តិកៈរបស់ **ឧ.ក.**

៨- លើការជួលជំនាញការ ឬ ការជួលបណ្តាញទូរគមនាគមន៍

៩- លើកិច្ចសន្យាស្របតាមប្រកាសលេខ ៩៩៧ សហវ.ទរ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ១៩៩៧ ស្តីពីលទ្ធកម្មសហគ្រាសសាធារណៈ ។

**មាត្រា៩.-**

ក្រុមប្រឹក្សាភិបាល បើកអង្គប្រជុំនៅពេលណាក៏បាន អាស្រ័យដោយអត្ថប្រយោជន៍នៃសហគ្រាស តាមការអញ្ជើញរបស់ប្រធាន ឬតាមសំណើនៃសមាជិកដែលមានចំនួន ៤ (បួន) នាក់ យ៉ាងតិចក្នុងចំណោមសមាជិកទាំងអស់។ ទោះបីជាយ៉ាងណាក៏ដោយ ក្រុមប្រឹក្សាភិបាលត្រូវធ្វើការប្រជុំយ៉ាងតិច មួយដងក្នុងរយៈពេល ៣ (បី) ខែ។

ករណីប្រធានមានធុរៈ ត្រូវជ្រើសរើសសមាជិកណាម្នាក់ដែលមានអាយុច្រើនជាងគេ ក្នុងចំណោមសមាជិកក្រុមប្រឹក្សាភិបាល ដែលមានវត្តមានដើម្បីដឹកនាំការប្រជុំ ។

ក្រុមប្រឹក្សាភិបាល ត្រូវពិភាក្សាលើបញ្ហាទាំងឡាយ ដែលស្ថិតក្នុងក្របខ័ណ្ឌរបស់ខ្លួន ។ របៀបវារៈនៃការប្រជុំ ព្រមទាំងឯកសារទាក់ទិនទាំងឡាយ ត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប និង មន្ត្រីត្រួតពិនិត្យរដ្ឋឱ្យបានយ៉ាងតិច១០( ដប់ថ្ងៃ មុនពេលបើកអង្គប្រជុំ ។ កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល អាចប្រព្រឹត្តទៅបាន លុះណាតែមានវត្តមានសមាជិកយ៉ាងតិច ៤( បួន) នាក់ ។ បើសិនជាមិនគ្រប់កូរ៉ុមទេ ការប្រជុំត្រូវលើកទៅ ១៥( ដប់ប្រាំ) ថ្ងៃ ក្រោយទៀត ដើម្បីពិភាក្សាលើបញ្ហាតាមរបៀបវារៈដដែល ។ កិច្ចប្រជុំលើកក្រោយនេះពុំបាច់ទាមទារកូរ៉ុមទេ ។ សេចក្តីសម្រេចទាំងឡាយ របស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសម្លេងភាគច្រើន នៃសមាជិកអង្គប្រជុំ ។ បើសិនជាការបែកសំឡេងមានចំនួនស្មើគ្នា សំឡេងរបស់ប្រធានក្រុមប្រឹក្សាភិបាល ឬប្រធានអង្គប្រជុំត្រូវចាត់ទុកជាឧត្តមានុភាព ។

**មាត្រា១០.–**

សេចក្តីសម្រេចនៃក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ ដែលត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាលទៅសមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និងមន្ត្រីត្រួតពិនិត្យរដ្ឋ ព្រមទាំងស្ថាប័នដទៃទៀតដែលមានចែងក្នុងមាត្រា ២២ នៃអនុក្រឹត្យនេះ ក្នុងរវាង ១៥( ដប់ប្រាំ) ថ្ងៃយ៉ាងយូរ ចាប់រាប់ពីថ្ងៃប្រជុំ ។

កំណត់ហេតុនៃកិច្ចប្រជុំ ត្រូវទទួលការយល់ព្រមពីក្រុមប្រឹក្សាភិបាល នាសម័យប្រជុំលើកក្រោយហើយ ត្រូវចម្លង ចូលបញ្ជីដែលមានលេខរៀងទំព័រជាប្រូវហែរ និងមានអត្តលេខចំណាំត្រឹមត្រូវ ។

កំណត់ហេតុដើមត្រូវមានចុះហត្ថលេខា ដោយប្រធានអង្គប្រជុំ សមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ ដែលវត្តមាន និង លេខាធិការជ្រើសរើសដោយអគ្គនាយក ។

**មាត្រា១១.–**

អគ្គនាយកមានភារកិច្ចជាអ្នកគ្រប់គ្រងការងារ ជាប្រក្រតីនៃ **ខ.ត.** នឹងត្រូវបានតែងតាំងសំរាប់អាណត្តិ ៣ (បី) ឆ្នាំ ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។ តំណែងនេះអាចបន្តទៅទៀតបាន តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ។

**មាត្រា១២.–**

ក្រុមប្រឹក្សាភិបាលណែនាំ និង ប្រគល់ឱ្យអគ្គនាយកនូវអំណាចចាំបាច់ទាំងឡាយ សម្រាប់ដំណើរការប្រចាំថ្ងៃ ដើម្បីមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការដឹកនាំសហគ្រាសស្របតាមច្បាប់ ។

ក្នុងមុខងារនេះ អគ្គនាយកមានភារកិច្ច ៖

១- រៀបចំឯកសារទាំងឡាយ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និង សម្រេច និង ចាត់ចែងអនុវត្តរាល់សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល តាមដំណាក់កាលនិមួយៗ និងត្រូវរាយការណ៍ជូន ក្រុមប្រឹក្សាភិបាលអំពីសកម្មភាពរបស់ **ឧ.ភ.**

២- ដឹកនាំ **ឧ.ភ.** លើផ្នែករដ្ឋបាល បច្ចេកទេសអាជីវកម្ម សេវាកម្ម និងហិរញ្ញវត្ថុ

៣- ជ្រើសរើស តែងតាំង ដកហូតតំណែង ឬបញ្ឈប់ការងារ និងគ្រប់គ្រងបណ្តាភ្នាក់ងារ ឬមន្ត្រីគ្រប់រូប ដែលជានិយោជិតរបស់ **ឧ.ភ.** ដោយគោរពតាមលក្ខន្តិកៈក្រុមហ៊ុន លក្ខន្តិកៈបុគ្គលិក ឬ ច្បាប់ជាធរមាន និងតាមការសសម្រេចរបស់ក្រុមប្រឹក្សាភិបាល

៤- ផ្ទេរអំណាចមួយភាគឬទាំងអស់ រួមទាំងការផ្ទេរសិទ្ធិចុះហត្ថលេខាទៅមន្ត្រី ដែលនៅក្រោមឱវាទស្របតាមល័ក្ខខ័ណ្ឌ ដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល

៥- ធ្វើជាតំណាងឱ្យ **ឧ.ភ.** និងទទួលខុសត្រូវចំពោះមុខតុលាការគ្រប់ជាន់ថ្នាក់ ក្នុងករណីចោទប្រកាន់តវ៉ាការពារក្តីឱ្យ **ឧ.ភ.** និងប្តឹងជំទាស់ផ្សេងៗ ។

**មាត្រា១៣._**

លាភការក្រុមប្រឹក្សាភិបាល និងប្រាក់បំណាច់របស់អគ្គនាយក ត្រូវកំណត់ដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

**មាត្រា១៤._**

ការចុះនិងអនុវត្តនីកិច្ចសន្យាដោយ**ឧ.ភ.** ត្រូវគោរពតាមបែបបទនិងនីតិវិធី ដែលកំណត់ដោយលក្ខន្តិកៈរបស់ក្រុមហ៊ុន និងច្បាប់ជាធរមាន ។

## ជំពូកទី ៣
## ការគ្រប់គ្រងហិរញ្ញវត្ថុ

**មាត្រា១៥._**

**ឧ.ភ.** កាន់កាប់គណនេយ្យរបស់ខ្លួន ឱ្យបានស្របតាមបទបញ្ជាគណនេយ្យកម្ពុជា និងតាមវិធាននៃគណនេយ្យដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៖

- ការិយបរិច្ឆេទគណនេយ្យចាប់ផ្តើមពីថ្ងៃទី ០១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី ៣១ ខែធ្នូ នៃឆ្នាំ ដដែល
- របាយការណ៍ហិរញ្ញវត្ថុត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល មុនថ្ងៃទី ៣១ ខែមិនា នៃការិយបរិច្ឆេទបន្ទាប់
- របាយការណ៍ហិរញ្ញវត្ថុ ត្រូវដាក់សុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងអំឡុងមិនលើសពី ១៥ (ដប់ប្រាំ) ថ្ងៃ រាប់ពីថ្ងៃដែលក្រុមប្រឹក្សាភិបាលបានពិនិត្យឯកសារទាំងឡាយ ។ ឯកសារទាំងនោះ ត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាលផងដែរ ដើម្បីសុំមតិទៅតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ១៦ នៃព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ
- មន្ត្រីត្រួតពិនិត្យរដ្ឋ ត្រូវបំពេញបេសកកម្ម ដោយអនុលោមតាមបទបញ្ញត្តិ នៃមាត្រា ២០ ២១ ២២ ២៣ ២៤ និងមាត្រា២៥ នៃព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ ។

**មាត្រា១៦.**_

រៀងរាល់ឆ្នាំ មុនថ្ងៃទី ០១ ខែតុលា ក្រុមប្រឹក្សាភិបាលត្រូវផ្តល់ការយល់ព្រមលើគម្រោងផែនការប្រចាំឆ្នាំរបស់**ឧ.ភ.**តាមសំណើរបស់អគ្គនាយកហើយបញ្ជូន ដើម្បីសុំការសម្រេចពីរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា១៧.**_

**ធនធាន** នៃ **ឧ.ភ.** ជាអាទិ៍មាន ៖

- ដើមទុនដែលរដ្ឋផ្តល់ឱ្យ (តុល្យការដំបូងនៅពេលបង្កើត)
- ប្រាក់ដើមទុនដែលរដ្ឋផ្តល់ឱ្យបន្ថែម
- ប្រាក់ចំណូលផ្សេងៗ គ្រប់ប្រភេទបានមកពីសកម្មភាពសេវាកម្មរបស់ **ឧ.ភ.**
- ប្រាក់បានមកពីការលក់ ឬជួលចលនវត្ថុ និងអចលនវត្ថុ របស់ **ឧ.ភ.**
- ប្រាក់បានមកពីការខ្ចីបុល និងប្រាក់អំណោយផ្សេងៗ ។

**មាត្រា១៨.**_

**ចំណាយ** នៃ **ឧ.ភ.** រួមមាន ៖

- ចំណាយប្រក្រតីសម្រាប់ដំណើរការ
- ចំណាយវិនិយោគ
- ចំណាយសងបំណុល
- ចំណាយផ្សេងៗ ។

**មាត្រា១៩.—**

**ឱ.ក.** អាចមានគណនីក្នុងធនាគារពាណិជ្ជកម្មផ្សេងៗ ហើយប្រើប្រាស់គណនីនេះ សម្រាប់តម្រូវការរបស់ខ្លួន ។

**មាត្រា២០.—**

**ឱ.ក.** ត្រូវបង់ប្រាក់ចំណូលដុលចូលថវិការដ្ឋ ៥១% (ហាសិបមួយភាគរយ) ពីសេវាទូរគមនាគមន៍អន្តរជាតិ ដូចច្រកចេញអន្តរជាតិទី២ និង ចំនួន៥% (ប្រាំភាគរយ) លើចំណូលទូរគមនាគមន៍ក្នុងប្រទេស និងសេវាតម្លៃបន្ថែម ។ ចំណែកឯប្រាក់ចំណេញ ត្រូវបង់ចូលថវិកាជាតិទាំងអស់ ឬមួយផ្នែក ឬរដ្ឋអាចរក្សាទុកទាំងអស់ឱ្យសហគ្រាស ក្នុងករណីដែលរដ្ឋពិនិត្យឃើញថា ធ្វើការអភិវឌ្ឍជាចាំបាច់ ។

**មាត្រា២១.—**

រដ្ឋធានាចំពោះតែបំណុលណា ដែលមានការយល់ព្រមជាមុន ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា២២.—**

រយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ យ៉ាងយូរបំផុតក្រោយពីការអនុម័តរបស់ក្រុមប្រឹក្សាភិបាល **ឱ.ក.** ត្រូវផ្ញើជូនរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នូវឯកសារដូចខាងក្រោមនេះ ៖

- កំណត់ហេតុប្រជុំក្រុមប្រឹក្សាភិបាល
- គម្រោងផែនការរបស់ **ឱ.ក.**
- របាយការណ៍សកម្មភាព-របាយការណ៍ហិរញ្ញវត្ថុទាំងឡាយរបស់ **ឱ.ក.** ។

**មាត្រា២៣.—**

ត្រូវបានដាក់ឱ្យនៅអម **ឱ.ក.** នូវមន្ត្រីត្រួតពិនិត្យរដ្ឋម្នាក់ ដែលត្រូវតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ មន្ត្រីត្រួតពិនិត្យរដ្ឋមានសិទ្ធិចូលរួមគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល ហើយអាចផ្តល់យោបល់លើគ្រប់ចំណុចនៃរបៀបវារៈតែពុំមានសម្លេងអនុម័តឡើយ ។ មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវបំពេញបេសកកម្ម ដោយអនុលោមតាមបទប្បញ្ញត្តិនៃមាត្រា ២០ ២១ ២២ ២៣ ២៤ និងមាត្រា២៥ នៃព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា២៤.—**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា២៥.—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៥ .

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២៥
- ឯកសារ-កាលប្បវត្តិ